ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គិសនីកម្ពុជា

លេខ : ៥៤១៣ ឤ៥៣.អក.អជ

# សេចក្តីជូនដំណឹង

**អគ្គិសនីកម្ពុជា**មានកិត្តិយស សូមទូលថ្វាយ និងជម្រាបជូន សម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី ដែលជាអតិថិជនរបស់អគ្គិសនីកម្ពុជាជ្រាបថា : ដើម្បីអនុវត្តការងារជួសជុល ផ្លាស់ប្តូរ តម្លើងបរិក្ខារ និងរុះរើខ្សែបណ្តាញបង្គោលក្នុងក្នុងអំឡុងពេលអនុវត្តការងារដល់ការដ្ឋានពង្រីកផ្លូវ អគ្គិសនីកម្ពុជានឹងផ្អាកការផ្គត់ផ្គង់អគ្គិសនី នៅតំបន់ភ្លើងមួយចំនួនទៅតាមពេលវេលា និងទីកន្លែងដូចខាងក្រោម :

១. ថ្ងៃព្រហស្បតិ៍ទី១៩ ខែមិថុនា ឆ្នាំ២០១៤ ចាប់ពីម៉ោង០៨ម៉ោ០០ ដល់ម៉ោង១៧ម៉ោ០០ នឹងផ្អាកការផ្គត់ផ្គង់អគ្គិសនី : (១)តំបន់ភ្លើងមួយចំនួនដែលស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខ៥ ចាប់ពីសង្កាត់គីឡូម៉ែត្រលេខ៦ រហូតដល់សង្កាត់ច្រាំងចំរេះ២ ក្នុងខណ្ឌឫស្សីកែវ (២)តំបន់ភ្លើងលេខ P020 ស្ថិតនៅភូមិខ្វារ ក្នុងសង្កាត់ដង្កោ ខណ្ឌដង្កោ និង (៣)តំបន់ភ្លើងមួយចំនួនដែលស្ថិតនៅភូមិចំពុះក្អែក ក្នុងសង្កាត់ព្រែកថ្មី ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ។

២. ថ្ងៃសុក្រទី២០ ខែមិថុនា ឆ្នាំ២០១៤ ចាប់ពីម៉ោង០៨ម៉ោ០០ ដល់ម៉ោង១៧ម៉ោ០០ នឹងផ្អាកការផ្គត់ផ្គង់អគ្គិសនី : (១)តំបន់ភ្លើងលេខ P020 ស្ថិតនៅភូមិខ្វារ ក្នុងសង្កាត់ដង្កោ ខណ្ឌដង្កោ (២)តំបន់ភ្លើងមួយចំនួនដែលស្ថិតនៅភូមិចំពុះក្អែក ក្នុងសង្កាត់ព្រែកថ្មី និង (៣)តំបន់ភ្លើងលេខ P988 ស្ថិតនៅក្នុងសង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ។

៣. ថ្ងៃសៅរ៍ទី២១ ខែមិថុនា ឆ្នាំ២០១៤ ចាប់ពីម៉ោង០៨ម៉ោ០០ ដល់ម៉ោង១៧ម៉ោ០០ នឹងផ្អាកការផ្គត់ផ្គង់អគ្គិសនី : (១)តំបន់ភ្លើងមួយចំនួនដែលស្ថិតនៅភូមិចំពុះក្អែក ក្នុងសង្កាត់ព្រែកថ្មី និង (២)តំបន់ភ្លើងមួយចំនួនដែលស្ថិតនៅតាមបណ្តោយផ្លូវវេងស្រេង ចាប់ពីភូមិទ្រា៣ ក្នុងសង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រហូតដល់ភូមិត្រពាំងថ្លឹង ក្នុងសង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ។

៤. ថ្ងៃអាទិត្យទី២២ ខែមិថុនា ឆ្នាំ២០១៤ ចាប់ពីម៉ោង០៨ម៉ោ០០ ដល់ម៉ោង១៧ម៉ោ០០ នឹងផ្អាកការផ្គត់ផ្គង់អគ្គិសនី : (១)តំបន់ភ្លើងមួយចំនួនដែលស្ថិតនៅតាមបណ្តោយផ្លូវជើងឯក ចាប់ពីភូមិសំបួរ ក្នុងសង្កាត់ដង្កោ រហូតដល់ភូមិព្រែកប្រណាក់ ក្នុងសង្កាត់ជើងឯក ខណ្ឌដង្កោ (២)តំបន់ភ្លើងមួយចំនួនដែលស្ថិតនៅភូមិត្រពាំងពោធិ ភូមិម្លប់ពោធិ ភូមិអណ្តូង ភូមិពុទ្រា ភូមិជ្រេស ភូមិកប់ស្រូវ ក្នុងសង្កាត់គោករកា ខណ្ឌព្រែកព្នៅ (៣)តំបន់ភ្លើងមួយចំនួនដែលស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខ៤ ចាប់ពីសង្កាត់កំបូល ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ រហូតដល់ឃុំដំណាក់អំពិល ក្នុងស្រុកអង្គស្នួល ខេត្តកណ្តាល និង (៤) តំបន់ភ្លើងមួយចំនួនដែលស្ថិតនៅតាមបណ្តោយផ្លូវវេងស្រេង ចាប់ពីភូមិទ្រា៣ ក្នុងសង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រហូតដល់ភូមិត្រពាំងថ្លឹង ក្នុងសង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ។

អាស្រ័យហេតុនេះ សូមសម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី ជ្រាបជាព័ត៌មាន និងសូមអធ្យាស្រ័យចំពោះការដាច់ចរន្តអគ្គិសនីនេះ ដោយអនុគ្រោះ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ២០១៤

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា**

**ទទួលបន្ទុកជា អគ្គនាយកអគ្គិសនីកម្ពុជា**

កែវ រតនៈ

អគ្គិសនីកម្ពុជា : # ២ ផ្លូវ ព្រះយុគន្ធរ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ : ០២៣ ៧២៣ ៩៧១ - ៧២៤ ៧៧១ ទូរសារ : (៨៥៥) ២៣ ៤២៦ ០១៨